


# ក្រសួងផែនការ

## អគ្គនាយកដ្ឋានផែនការ

## នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

សេចក្ដីណែនាំ

# ស្ដីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ
លេខ០១៤៥ផក

ថ្ងៃ ច័ន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០២២

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

### ១. សេចក្តីផ្តើម និង វត្ថុបំណង

នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការមានភារកិច្ចដឹកនាំ និងគ្រប់គ្រងការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។

យោងតាមសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការឯកភាពជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដាក់ចេញវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ រាជរដ្ឋាភិបាលបានចង្អុលបង្ហាញដល់ក្រសួងស្ថាប័នពាក់ព័ន្ធឱ្យអនុវត្តវិធានការគោលនយោបាយចំនួន៦ ដើម្បីឆ្លើយតបនឹងមេរោគអេដស៍។ គោលនយោបាយទី២ ក្នុងចំណោមគោលនយោបាយចំនួន៦ បានលើកឡើងថា ក្រសួងផែនការ និងក្រសួងសុខាភិបាល រៀបចំនិងចាត់ទុកថា អ្នកផ្ទុកមេរោគអេដស៍ជាក្រុមប្រជាជនងាយរងគ្រោះដែលត្រូវទទួលបណ្ណសមធម៌ ដើម្បីធានាដល់ការទទួលបានសេវាថែទាំសុខភាព និងការគាំពារសង្គម។

ការផ្តល់បណ្ណសមធម៌ជូនអ្នកផ្ទុកមេរោគអេដស៍ គឺស្របជាមួយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពឆ្លើយតបនឹងមេរោគអេដស៍ និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពស្ថាប័ន ដើម្បីត្រៀមជាស្រេចក្នុងការផ្តល់សេវាសង្គមដល់អ្នកផ្ទុកមេរោគអេដស៍តាមរយៈការផ្តល់សេវាថែទាំសុខភាព ការផ្តល់អន្តរាគមន៍សេវាសង្គមនានាក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការបានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរ

ស្បែក និងកាមរោគនៃក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ រួមមាន GIZ UNDP និងUNAIDS បានរៀបចំឱ្យមានសេចក្តីណែនាំនេះ ក្នុងគោលបំណងកំណត់អំពីយន្តការ និងនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នេះឡើង។

មន្ត្រីបង្គោលទទួលបន្ទុកការងារចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅតាមគ្លីនិកផ្តល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (គ្លីនិកART) ដែលចាត់តាំងដោយប្រធានមន្ទីរពេទ្យ ឬប្រធានគ្លីនិក ក្រោមការពិភាក្សាជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគត្រូវធ្វើការងារនេះ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលពីមន្ត្រីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ។

ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ត្រូវអនុវត្តតាមសេចក្តីណែនាំ ដូចខាងក្រោម៖

## ២. ការបណ្តុះបណ្តាល

ក្រុមការងារនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវសហការ និងសម្របសម្រួលជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគនៃក្រសួងសុខាភិបាល និងអ្នកមានចំណែកពាក់ព័ន្ធរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលទទួលបន្ទុកការងារចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ពាក់ព័ន្ធទាំងអស់។

## ៣. ជំហានអនុវត្ត

ដំណើរការអនុវត្តនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍រួមមាន (១)ដំណើរការផ្តល់បណ្ណសមធម៌ជូនអ្នកផ្ទុកមេរោគអេដស៍ និង (២)ដំណើរការដកបណ្ណសមធម៌ពីអ្នកផ្ទុកមេរោគអេដស៍។

ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ត្រូវអនុវត្តដូចខាងក្រោម៖

### ៣.១. ដំណើរការផ្តល់បណ្ណសមធម៌ជូនអ្នកផ្ទុកមេរោគអេដស៍

កិច្ចដំណើរការផ្តល់បណ្ណសមធម៌ជូនអ្នកផ្ទុកមេរោគអេដស៍ ត្រូវអនុវត្តជាប្រចាំដោយមន្ត្រីបង្គោលទទួលបន្ទុកចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដោយមានការគាំទ្រពីអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត។



### ៣.១.១. ជំហានទី១៖ ការពិនិត្យបណ្ណសមធម៌របស់អតិថិជន

ជាធម្មតាអតិថិជនទៅរកសេវាសុខភាពនៅតាមគ្លីនិកART តាមការណាត់របស់គ្រូពេទ្យ។ អ្នកសម្ភាសន៍ត្រូវទទួលរាក់ទាក់អតិថិជនរបស់ខ្លួន ដោយការចាប់ផ្ដើមនូវពាក្យគួរសមមួយចំនួននៅមុនពេលសាកសួរព័ត៌មានដើម្បីទទួលបានព័ត៌មានថាតើ អតិថិជនរបស់ខ្លួនមានបណ្ណសមធម៌ ឬ ជាសមាជិកនៃគ្រួសារដែលមានបណ្ណសមធម៌ដែរឬទេ?

(១)ករណីអតិថិជនរបស់ខ្លួនមានបណ្ណសមធម៌ ឬ ជាសមាជិកនៃគ្រួសារដែលមានបណ្ណសមធម៌នៅមានសុពលភាព៖ អ្នកសម្ភាសន៍ត្រូវកត់ត្រាពីលេខបណ្ណសមធម៌ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានលើបណ្ណសមធម៌ទៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការ អំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់សមាជិកគ្រួសារ និងធ្វើបច្ចុប្បន្នកម្មព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍។ បន្ទាប់មកធ្វើបច្ចុប្បន្នកម្មទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ដែលនឹងមានរៀបរាប់លម្អិតនៅក្នុងផ្នែកការធ្វើបច្ចុប្បន្នកម្មទិន្នន័យអ្នកផ្ទុកមេរោគអេដស៍។

(២)ករណីអតិថិជនមិនទាន់មានបណ្ណសមធម៌ ឬមានកាន់បណ្ណសមធម៌ផុតសុពលភាព៖ អ្នកសម្ភាសន៍ ត្រូវផ្ដល់ការណែនាំដល់អតិថិជនរបស់ខ្លួនអំពីទម្រង់ និងអត្ថប្រយោជន៍នៃបណ្ណសមធម៌ និងលក្ខខណ្ឌមួយចំនួនដែលអតិថិជនត្រូវចូលរួមដោយស្ម័គ្រចិត្ត ដូចជា ត្រូវបំពេញពាក្យយល់ព្រមផ្ដល់សម្ភាសន៍(ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១) និងការផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណរបស់អតិថិជន។ ជាចុងក្រោយអ្នកសម្ភាសន៍ត្រូវសួរបញ្ជាក់អតិថិជន ថាតើចង់បានបណ្ណសមធម៌ដែរឬទេ?

(ក)ករណីអតិថិជនមិនចង់បានបណ្ណសមធម៌៖ អ្នកសម្ភាសន៍ត្រូវលើកទឹកចិត្តអតិថិជន និងស្ទាបស្ទង់មើលថាតើអតិថិជនមានមតិយោបល់អ្វីខ្លះមកកាន់គ្លីនិកART បន្ទាប់មកបិទបញ្ចប់នីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ត្រឹមនេះ។ អ្នកសម្ភាសន៍ត្រូវយកចិត្តទុកដាក់សាកសួរ និងផ្ដល់ព័ត៌មានបន្ថែមដល់អតិថិជននេះ នៅពេលដែលពួកគាត់ត្រឡប់មកទទួលសេវាសុខភាពតាមការណាត់លើកក្រោយទៀត។

(ខ)ករណីអតិជនចង់បានបណ្ណសមធម៌៖ អ្នកសម្ភាសន៍ត្រូវបន្តនីតិវិធីក្នុងជំហានទី២ (ការបំពេញពាក្យយល់ព្រមផ្ដល់សម្ភាសន៍) ជំហានទី៣ (ការសម្ភាសន៍) ដូចខាងក្រោម៖

### ៣.១.២. ជំហានទី២៖ ការបំពេញពាក្យយល់ព្រមផ្ដល់សម្ភាសន៍

- អតិថិជនមកទទួលសេវានៅគ្លីនិកART ដែលមិនមានបណ្ណសមធម៌ ឬបណ្ណសមធម៌ផុតសុពលភាព ហើយមានបំណងចង់បានបណ្ណសមធម៌ពីគ្លីនិកART ត្រូវបំពេញពាក្យយល់ព្រមផ្ដល់សម្ភាសន៍ រួចចុះហត្ថលេខា ឬផ្ដិតមេដៃស្ដាំនៅមុនពេលចាប់ផ្ដើមការសម្ភាសន៍។ ករណីមិនអាចបំពេញពាក្យដោយខ្លួនឯងបាន អតិថិជន ត្រូវស្នើសុំជំនួយពីអ្នកសម្ភាសន៍។

- អ្នកសម្ភាសន៍ត្រូវពិនិត្យពាក្យយល់ព្រមផ្តល់សម្ភាសន៍ និងអានជូនអតិថិជនស្តាប់នៅមុនពេលចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ ដើម្បីធានាថាទាំងអតិថិជនទាំងអ្នកសម្ភាសន៍បានយល់ពីការរក្សាទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ជាការសំងាត់បំផុត
- អ្នកសម្ភាសន៍ ត្រូវរក្សាទុកពាក្យយល់ព្រមផ្តល់សម្ភាសន៍ក្នុងទូរឯកសារដែលមានសោរចាក់យ៉ាងត្រឹមត្រូវ។

### ៣.១.៣. ជំហានទី៣៖ ការសម្ភាសន៍

- អ្នកសម្ភាសន៍ ត្រូវប្រើប្រាស់គណនីរបស់ខ្លួនដើម្បីចូលទៅក្នុងមុខងារសម្ភាសន៍ដែលមាននៅក្នុងអែបចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍(PLHIV Registration App) សម្រាប់ការងារសម្ភាសន៍ និងបំពេញព័ត៌មានដែលទទួលបានពីអតិថិជនអ្នកផ្តល់សម្ភាសន៍
- អ្នកសម្ភាសន៍ត្រូវប្រើប្រាស់ឧបករណ៍វៃឆ្លាតសម្រាប់កត់ត្រាព័ត៌មាន ដែលបានផ្តល់ពីអតិថិជន ដែលបានយល់ព្រមផ្តល់សម្ភាសន៍សម្រាប់ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានបណ្ណសមធម៌កម្រិតបុគ្គល និងមានការបញ្ជាក់ទទួលស្គាល់ដោយគ្លីនិកART
- អ្នកសម្ភាសន៍ត្រូវបង្កើតករណីដោយបំពេញព័ត៌មានអតិថិជនដែលបានបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍ចូលទៅក្នុងឧបករណ៍វៃឆ្លាតរបស់ខ្លួនសម្រាប់បន្ត
- អ្នកសម្ភាសន៍ត្រូវពិនិត្យករណីដែលខ្លួនបានបង្កើតរួចនូវព័ត៌មានអំពីអត្តសញ្ញាណបុគ្គលផ្តល់សម្ភាសន៍ និងធ្វើការកែតម្រូវដោយសួរបញ្ជាក់អតិថិជនផ្តល់សម្ភាសន៍
- អ្នកសម្ភាសន៍ត្រូវអានខ្លឹមសារដែលបង្ហាញពីការយល់ព្រមផ្តល់សម្ភាសន៍ឱ្យអតិថិជនផ្តល់សម្ភាសន៍បានស្តាប់លឺ និងយល់ពីខ្លឹមសារទាំងអស់ដូចខាងក្រោម៖
    - ខ្ញុំសូមបញ្ជាក់ថា ការចូលរួមរបស់ខ្ញុំក្នុងដំណើរការនេះគឺជាការស្ម័គ្រចិត្ត។ ខ្ញុំបានយល់ពីការពន្យល់ដែលបានផ្តល់ឱ្យខ្ញុំ ជាពិសេសគឺថា៖

        ១- ក្រសួងផែនការជាអ្នកគ្រប់គ្រង និងប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ក្នុងការទទួលបានបណ្ណសមធម៌គឺការសម្ភាសន៍ត្រូវសួរសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល និងព័ត៌មានដទៃទៀត

        ២- ព័ត៌មានរបស់បុគ្គលដែលបានមកពីការផ្តល់ក្នុងពេលសម្ភាសន៍នេះ នឹងត្រូវរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការរហូតដល់មានការសម្ភាសន៍លោក លោកស្រីឡើងវិញ។

៣- មូលដ្ឋានទិន្នន័យក្រសួងផែនការ នឹងរក្សាទិន្នន័យជាការសំងាត់ និងចែករំលែកជាមួយនឹងស្ថាប័ន អង្គការនានាដែលមានសិទ្ធផ្តល់សេវាផ្សេងៗទៅដល់អ្នកផ្ទុកមេរោគអេដស៍តែប៉ុណ្ណោះ។

- ពេលអានចប់ អ្នកសម្ភាសន៍ត្រូវសួរបញ្ជាក់ទៅអតិថិជនអ្នកផ្តល់សម្ភាសន៍ថាតើលោកលោកស្រីយល់ព្រមផ្តល់សម្ភាសន៍ដែរឬទេ?
  - បើចម្លើយ មិនយល់ព្រម៖ អ្នកសម្ភាសន៍ត្រូវបញ្ចប់នីតិវិធីត្រឹមនេះ
  - បើចម្លើយយល់ព្រម៖ អ្នកសម្ភាសន៍ត្រូវបន្តការសម្ភាសន៍ និងបំពេញព័ត៌មានដល់ចប់
- អ្នកសម្ភាសន៍ត្រូវផែកមើលឡើងវិញ(និងធ្វើការកែតម្រូវបើមាន)នូវព័ត៌មានដែលបានបំពេញរួច និងបញ្ជូនមករក្សាទុកក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ(វានឹងបង្ហាញប្រាប់ថា ករណី" **ថ្មី**" )សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ និងអនុម័ត។

## ៣.១.៤. ជំហានទី៤៖ ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងអនុម័ត

- មន្ត្រីពិនិត្យផ្ទៀងផ្ទាត់ ត្រូវប្រើប្រាស់គណនីរបស់ខ្លួនដើម្បីចូលទៅក្នុងមុខងារពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញរួចនៅក្នុងមូលដ្ឋានទិន្នន័យ(ករណី" **ថ្មី**" )។ បន្ទាប់ពីមន្ត្រីពិនិត្យផ្ទៀងផ្ទាត់រួចទិន្នន័យអ្នកផ្ទុកមេរោគអេដស៍វាបង្ហាញប្រាប់ថាករណី " **បានពិនិត្យរួច** "។ មូលដ្ឋាន ទិន្នន័យនឹងបញ្ជូនករណី " **បានពិនិត្យរួច** " មកមន្ត្រីអនុម័ត។
- មន្ត្រីអនុម័ត ត្រូវប្រើប្រាស់គណនីរបស់ខ្លួនដើម្បីចូលទៅក្នុងមុខងារអនុម័តព័ត៌មានដែលបានពិនិត្យផ្ទៀងផ្ទាត់រួចនៅក្នុងមូលដ្ឋានទិន្នន័យ(ករណី " **បានពិនិត្យរួច** " )។ មន្ត្រីអនុម័តមានសិទ្ធ " **បដិសេធ** " ឬ " **ឯកភាព** " ចំពោះករណីដែលបានពិនិត្យរួចដោយមន្ត្រីពិនិត្យផ្ទៀតផ្ទាត់។
- ទិន្នន័យករណីដែលបាន " **បដិសេធ** " មន្ត្រីអនុម័តត្រូវបំពេញព័ត៌មានពីមូលហេតុនៃការបដិសេធរបស់ខ្លួននិងបញ្ជូនព័ត៌មាននេះមកមន្ត្រីពិនិត្យផ្ទៀតផ្ទាត់ដើម្បីពិនិត្យនិងកែសម្រួលករណី" **ថ្មី**" ឡើងវិញរួចបញ្ជូនមកមន្ត្រីអនុម័តម្តងទៀត។
- ទិន្នន័យករណីដែលបាន " **ឯកភាព** " ត្រូវបញ្ជូន និងផ្តល់ព័ត៌មានដល់មន្ត្រីពិនិត្យផ្ទៀតផ្ទាត់ដើម្បីផលិតបណ្ណសមធម៌។

### ៣.១.៥. ជំហានទី៥៖ ការបោះពុម្ព និងការផ្តល់បណ្ណសមធម៌

ប្រព័ន្ធមូលដ្ឋានទិន្នន័យក្រសួងផែនការ នឹងផលិតបណ្ណសមធម៌សម្រាប់មន្ត្រីពិនិត្យផ្ទៀងផ្ទាត់អាចបោះពុម្ព និងផ្តល់ជូនមន្ត្រីអនុម័តចុះហត្ថលេខា និងបោះត្រា ដើម្បីចែកជូនដល់អតិថិជន។

<u>**កំណត់សម្គាល់៖**</u> បណ្ណសមធម៌ដែលចេញដោយគ្លីនិកART មិនមានកាលបរិច្ឆេទផុតសុពលភាពឡើយ។

## ៣.២. ដំណើរការដកបណ្ណសមធម៌ពីអ្នកផ្ទុកមេរោគអេដស៍

ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ ត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំ។

អតិថិជនដែលមកទទួលសេវាសុខភាពនៅគ្លីនិកART អាចប្រើប្រាស់បណ្ណសមធម៌ជាលក្ខណៈបុគ្គលដែលចេញដោយគ្លីនិកART ឬបណ្ណសមធម៌ជាលក្ខណៈគ្រួសារដែលចេញដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងករណីដែលអតិថិជនមានបណ្ណសមធម៌ជាលក្ខណៈបុគ្គលដែលចេញដោយគ្លីនិកART អ្នកសម្ភាសន៍ ត្រូវសួរអតិថិជនថា តើបីខែកន្លងមកគ្រួសាររបស់លោក លោកស្រី មានទទួលបានបណ្ណសមធម៌ពីឃុំ សង្កាត់ដែរឬទេ ? ប្រសិនបើអតិថិជន ផ្តល់ចម្លើយថា **បានទទួល** អ្នកសម្ភាសន៍ ត្រូវពិនិត្យផ្ទៀងផ្ទាត់បណ្ណសមធម៌នៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវពិតប្រាកដនៃបណ្ណសមធម៌ជាលក្ខណៈគ្រួសារ។ បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់ថាអតិថិជនមានបណ្ណសមធម៌ពីរក្នុងពេលមកទទួលសេវាសុខភាពនៅគ្លីនិកART អ្នកសម្ភាសន៍ ត្រូវតែដកបណ្ណសមធម៌ជាលក្ខណៈបុគ្គលចេញពីអតិថិជន(មានន័យថា ត្រូវរក្សាទុកបណ្ណសមធម៌ជាលក្ខណៈគ្រួសារដែលចេញដោយក្រុមប្រឹក្សាឃុំ សង្កាត់)។

អ្នកមានចំណែកពាក់ព័ន្ធ នឹងកិច្ចដំណើរការនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ មានសិទ្ធិស្នើសុំដកបណ្ណសមធម៌ជាលក្ខណៈបុគ្គលដែលចេញដោយគ្លីនិកART បានក្នុងករណីអ្នកផ្ទុកមេរោគអេដស៍ មានបណ្ណសមធម៌ជាលក្ខណៈគ្រួសារដែលចេញដោយឃុំ សង្កាត់។

# ៤. ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងមតិជំទាស់និងសំណូមពរ

ការតាមដានត្រួតពិនិត្យ និងការដោះស្រាយមតិជំទាស់ និងសំណូមពរ ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់របស់ក្រសួងផែនការ។

# ៥. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

## ៥.១. ក្រសួងផែនការ

- រៀបចំសេចក្តីណែនាំ និងសម្របសម្រួលដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- កៀរគរធនធានសម្រាប់គាំទ្រដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍

- រៀបចំឯកសារ និងសម្ភារបណ្តុះបណ្តាល និងសម្ភារផ្សព្វផ្សាយការយល់ដឹងអំពីការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ដល់អ្នកមានចំណែកពាក់ព័ន្ធ
- ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារ និងអ្នកមានចំណែកពាក់ព័ន្ធ
- រៀបចំ ប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ជាតិ និងផ្តល់ទិន្នន័យតាមរយៈ API ដល់ស្ថាប័នពាក់ព័ន្ធ និងដៃគូផ្តល់សេវានានាតាមការស្នើសុំដោយធានាការការពារនិងរក្សាការសំងាត់ទិន្នន័យ
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធដែលធ្វើការងារផ្នែកគាំពារសង្គម និងជំនួយបន្ទាន់នានា
- តាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ផ្តល់ការណែនាំដល់មន្ទីរវេជ្ជសាស្ត្ររាជធានី ខេត្ត ក្នុងការចុះជួយគាំទ្រការអនុវត្តរបស់មន្ត្រីបង្គោលទទួលបន្ទុកការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ក្នុងដែនរាជធានី ខេត្តរបស់ខ្លួន
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

## ៥.២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- ផ្តល់ការណែនាំអំពីគោលនយោបាយ និងការសម្របសម្រួលទូទៅសម្រាប់កិច្ចគាំពារសង្គមសម្រាប់អ្នកផ្ទុកមេរោគអេដស៍
- កៀរគរធនធានសម្រាប់គាំទ្រដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ទទួល និងប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍
- សហការ និងសម្របសម្រួលជាមួយអ្នកមានចំណែកពាក់ព័ន្ធដើម្បីធានាថាអ្នកផ្ទុកមេរោគអេដស៍ទទួលបានប័ណ្ណសមធម៌
- ស្វែងរក និងពិគ្រោះយោបល់ជាមួយអ្នកមានចំណែកពាក់ព័ន្ធដើម្បីផ្តល់ជំនួយសង្គមដល់អ្នកផ្ទុកមេរោគអេដស៍
- ចូលរួមតាមដានត្រួតពិនិត្យតាមដានកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- គាំទ្រការលើកកំពស់ការយល់ដឹងដល់អ្នកមានចំណែកពាក់ព័ន្ធ
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

## ៥.៣. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

- ដឹកនាំ សហការ គាំទ្របច្ចេកទេសសម្រាប់ដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅគ្លីនិកART
- សហការ និងសម្របសម្រួលជាមួយក្រសួងផែនការរៀបចំសកម្មភាពពង្រឹងសមត្ថភាពដល់មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកនៅតាមគ្លីនិកART(អំពីកិច្ចដំណើរការចុះឈ្មោះ អំពីការប្រើប្រាស់កម្មវិធីសម្រាប់ចុះឈ្មោះ និងការត្រួតពិនិត្យគុណភាពព័ត៌មានដែលបានកត់ត្រា)
- ធានាថាអតិថិជនដែលគ្មានប័ណ្ណសមធម៌នៅមានសុពលភាព នៅពេលមកទទួលសេវានៅគ្លីនិកART មានសិទ្ធិចុះឈ្មោះដោយស្ម័គ្រចិត្តដើម្បីទទួលបានបណ្ណសមធម៌
- ជម្រុញដល់ប្រធានគ្លីនិកARTទាំងអស់ត្រូវយកចិត្តទុកដាក់ដល់អតិថិជនដែលគ្មានប័ណ្ណសមធម៌បានចុះឈ្មោះតាមការស្ម័គ្រចិត្ត
- ផ្តល់បរិក្ខារ និងសម្ភារ(ដូចជា កុំព្យូទ័រ ព្រីនធើ និងទឹកថ្នាំកូល័រ ក្រដាសបោះពុម្ពប័ណ្ណសមធម៌)ដល់គ្លីនិកART
- តាមដានត្រួតពិនិត្យកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងចែករំលែកអំពីបញ្ហាដែលកើតមាន និងរកដំណោះស្រាយផ្សេងៗជាមួយក្រុមការងារ
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- រៀបចំ និងគ្រប់គ្រងបញ្ជីឈ្មោះមន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ បង្កើតគណនីអ្នកប្រើប្រាស់ចូលទៅមុខងាររបស់ខ្លួន។ មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ មានសមាសភាព និងភារកិច្ចអនុវត្តដូចខាងក្រោមៈ

### ក. អ្នកសម្ភាសន៍

- ពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានលើបណ្ណសមធម៌នៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់សមាជិកគ្រួសារ និងធ្វើបច្ចុប្បន្នកម្មព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍
- ផ្តល់ប្រឹក្សា និងពន្យល់ណែនាំដល់អតិថិជនដែលមកទទួលសេវាសុខភាពនៅគ្លីនិកART អំពីដំណើរការ និងអត្ថប្រយោជន៍នៃការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ពន្យល់ពីការរក្សាការសំងាត់នូវទិន្នន័យដែលបានប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍

- ពន្យល់អំពីសិទ្ធរបស់អតិថិជន ក្នុងការចូលរួមដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - បញ្ជូនឈ្មោះអតិថិជន (ករណី "**ថ្មី**")ដែលបានសម្ភាសន៍រួចទៅមន្ត្រីផ្ទៀងផ្ទាត់
  - ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

### ខ. មន្ត្រីផ្ទៀងផ្ទាត់

- ផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការសម្ភាសន៍(បញ្ជីឈ្មោះអតិថិជនដែលបានសម្ភាសន៍ ករណី "**ថ្មី**")
- កែសម្រួលព័ត៌មាន ករណីរកឃើញមានចំណុចខុសឆ្គង
- បញ្ជូនឈ្មោះអតិថិជនដែលបានផ្ទៀងផ្ទាត់ទិន្នន័យរួច(ករណី "**បានពិនិត្យរួច**")ទៅមន្ត្រីអនុម័ត
- បោះពុម្ពបណ្ណសមធម៌ជូនអតិថិជន បន្ទាប់ពីទទួលបានការអនុម័តរួច
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

### គ. មន្ត្រីអនុម័ត

- ទទួល និងអនុម័តឈ្មោះអតិថិជន(ករណី "**បានពិនិត្យរួច**")ដែលបានបញ្ជូនមកពីមន្ត្រីផ្ទៀងផ្ទាត់ទិន្នន័យ
- បញ្ជូនឈ្មោះអតិថិជនដែលបានអនុម័តរួច(ករណី "**ឯកភាព**")ទៅមន្ត្រីផ្ទៀងផ្ទាត់ដើម្បីបោះពុម្ពបណ្ណសមធម៌
- ចុះហត្ថលេខា និងបោះត្រាលើបណ្ណសមធម៌សម្រាប់ចែកជូនអតិថិជនរបស់ខ្លួន
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

## ៥.៤. អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត

អ្នកមានចំណែកពាក់ព័ន្ធដទៃផ្សេងទៀតមានភារកិច្ច ដូចខាងក្រោម៖

- ចែករំលែក និងចូលរួមបង្កើនការយល់ដឹងដល់ក្រុមគោលដៅអំពីកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ អំពីរបៀបចុះឈ្មោះដោយស្ម័គ្រចិត្ត អំពីការរក្សាការសំងាត់ និងការផ្តល់សំណូមពរ ឬភាពមិនប្រក្រតីនានាដែលកើតមានឡើងក្នុងពេលអនុវត្ត

- ជួយសម្របសម្រួល និងផ្ដល់ការគាំទ្រដល់ការងារពាក់ព័ន្ធនឹងការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍(ស្ម័គ្រចិត្តធ្វើជាមន្ត្រីបង្គោលចុះឈ្មោះតាមការស្នើសុំពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ)
- អាចផ្ដល់ជាធនធានផ្សេងៗតាមការស្ម័គ្រចិត្តសម្រាប់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគ

  អេដស៍(ការពង្រឹងសមត្ថភាព ការលើកកម្ពស់ការយល់ដឹងដល់ក្រុមគោលដៅ ការផ្ដល់ឧបករណ៍ និងសម្ភារដល់គ្លីនិកសេវាART ។ល។)
- ស្នើសុំទិន្នន័យពីក្រសួងផែនការ ដើម្បីទទួលបាន និងប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍សម្រាប់ការផ្ដល់សេវាសង្គម និងកិច្ចអន្តរាគមន៍នានាដោយធានារក្សាការសំងាត់បំផុត
- ពង្រឹង និងពង្រីកលទ្ធភាពផ្ដល់សេវាគាំពារសង្គមចាំបាច់នានាដល់អ្នកផ្ទុកមេរោគអេដស៍
- អាចចូលរួមតាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកិច្ចដំណើរការ

  ចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

អ្នកមានចំណែកពាក់ព័ន្ធដទៃទៀតដែលចូលរួមនៅក្នុងកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នេះ មានជាអាទិ៍៖

- អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល
- តំណាងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល(ជាតិ និងអន្តរជាតិ) សង្គមស៊ីវិល និងតំណាងសហគមន៍ដែលធ្វើការផ្ដល់សេវាដល់អ្នកផ្ទុកមេរោគអេដស៍
- អ្នកធ្វើកិច្ចការផ្ដល់សេវាសង្គមដល់អ្នកផ្ទុកមេរោគអេដស៍
- បណ្ដាញអ្នករស់នៅជាមួយមេរោគអេសដ៍
- អ្នកដឹកនាំសាសនា
- ... ។ ល។

## ៦. ការរក្សាការសំងាត់នៃទិន្នន័យអ្នកផ្ទុកមេរោគអេដស៍

ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ត្រូវបានរក្សាការពារត្រឹមត្រូវ និងហ្មត់ចត់ក្នុងន័យរក្សាការសំងាត់នៃព័ត៌មានបុគ្គល និងត្រូវប្រើប្រាស់សម្រាប់គោលបំណងផ្ដល់អន្តរាគមន៍សេវាសង្គមតែប៉ុណ្ណោះ។ កម្រិតនៃការចូលទៅប្រើប្រាស់ព័ត៌មាននឹងត្រូវបានកំណត់ទៅតាមកម្រិតនៃការទទួលខុសត្រូវ និងភាពពាក់ព័ន្ធរបស់អ្នកអនុវត្ត និងប្រើប្រាស់ទិន្នន័យនីមួយៗ ហើយត្រូវធានាព័ត៌មានបុគ្គលអ្នកផ្ទុកមេរោគអេដស៍នឹងត្រូវបានរក្សាជាការសំងាត់ខ្ពស់បំផុត។

មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវធានារក្សាការសំងាត់ទិន្នន័យដែលបានប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

អ្នកគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ត្រូវធានាការរក្សាសុវត្ថិភាពទិន្នន័យ និងចៀសវាងការបែកធ្លាយឬការចែកចាយទិន្នន័យដែលផ្ទុយពីគោលការណ៍រក្សាការសំងាត់នៃទិន្នន័យដែលទទួលបានពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

អ្នកប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ ត្រូវធានារក្សាការពារទិន្នន័យទាំងនេះ និងធានាថាមិនមានការចែកបន្តទៅភាគីទី៣ដោយមិនមានការអនុញ្ញាតពីក្រសួងផែនការឡើយ។

សេចក្ដីលម្អិតអំពីការរក្សាការសំងាត់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ សូមមើលឯកសារនិយាមប្រតិបត្តិសម្រាប់រក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គល។

## ៧. ការអនុវត្តការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍

អ្នកដែលមានចំណែកពាក់ព័ន្ធ ដូចមានចែងក្នុងសេចក្ដីណែនាំស្ដីពីការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

# ពាក្យយល់ព្រមផ្តល់សម្ភាសន៍

សូមគោរពជូនលោក លោកស្រីប្រធានគ្លីនិកART..................................

**កម្មវត្ថុ** ៖ ករណីយល់ព្រមផ្តល់សម្ភាសន៍សម្រាប់ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅគ្លីនិកART។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ......... អាយុ......... មានទីលំនៅបច្ចុប្បន្នភូមិ.................. ឃុំ.................. ស្រុក..................... ខេត្ត......................... សូមបញ្ជាក់ថា ការចូលរួមរបស់ខ្ញុំក្នុងដំណើរការនេះគឺជាការស្ម័គ្រចិត្ត។ ខ្ញុំបានយល់ពីការពន្យល់ដែលបានផ្តល់ឱ្យខ្ញុំ ជាពិសេសគឺថា៖

១- ក្រសួងផែនការ ជាអ្នកគ្រប់គ្រង និងប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ក្នុងការទទួលបានបណ្ណសមធម៌គឺការសម្ភាសន៍ត្រូវសួរសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងព័ត៌មានអំពីអត្តសញ្ញាណបុគ្គល និងព័ត៌មានមួយចំនួនទៀត។

២- ព័ត៌មានរបស់បុគ្គលដែលបានមកពីការផ្តល់ក្នុងពេលសម្ភាសន៍នេះ នឹងត្រូវរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការរហូតដល់មានការសម្ភាសន៍លោក លោកស្រីឡើងវិញ។

៣- មូលដ្ឋានទិន្នន័យក្រសួងផែនការ នឹងរក្សាទិន្នន័យជាការសំងាត់ និងចែករំលែកជាមួយនឹងស្ថាប័ន អង្គការនានាដែលមានសិទ្ធផ្តល់សេវាផ្សេងៗទៅដល់អ្នកផ្ទុកមេរោគអេដស៍តែប៉ុណ្ណោះ។

ខ្ញុំយល់ព្រម និងផ្តល់ព័ត៌មានអំពីអត្តសញ្ញាណទាំងស្រុងរបស់ខ្ញុំក្នុងការសម្ភាសន៍សម្រាប់ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

☐ មិនយល់ព្រម ☐ យល់ព្រម

ថ្ងៃទី........ ខែ................. ឆ្នាំ២០២.....

ហត្ថលេខា ឬស្នាមមេដៃស្តាំ................

ឈ្មោះ....................................

ឧបសម្ព័ន្ធទី២

## បញ្ជីឈ្មោះអ្នកសម្ភាសន៍ មន្ត្រីផ្ទៀងផ្ទាត់ និងមន្ត្រីអនុម័ត

រាជធានី ខេត្ត៖ ........................ ក្រុង ស្រុក ខណ្ឌ៖ ......................ឃុំ សង្កាត់៖ .........................

ភារកិច្ច និងការទទួលខុសត្រូវ៖

- **អ្នកសម្ភាសន៍៖**
  - ✓ ពិនិត្យផ្ទៀងផ្ទាត់ប័ណ្ណសមធម៌នៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់សមាជិកគ្រួសារ និងធ្វើបច្ចុប្បន្នកម្មព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដសន៍
  - ✓ ផ្តល់ប្រឹក្សា និងពន្យល់ណែនាំដល់អតិថិជនដែលមកទទួលសេវាសុខភាពនៅគ្លីនិកART អំពីដំណើរការ និងអត្ថប្រយោជន៍នៃការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ ពន្យល់ពីការរក្សាការសំងាត់នូវទិន្នន័យដែលបានប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ ពន្យល់អំពីសិទ្ធរបស់អតិថិជន ក្នុងការចូលរួមដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ បញ្ជូនឈ្មោះអតិថិជន (ករណី " ថ្មី")ដែលបានសម្ភាសន៍រួចទៅមន្ត្រីផ្ទៀងផ្ទាត់
  - ✓ ត្រូវរក្សាសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។
- **មន្ត្រីផ្ទៀងផ្ទាត់៖**
  - ✓ ផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការសម្ភាសន៍(បញ្ជីឈ្មោះអតិថិជនដែលបានសម្ភាសន៍ករណី " ថ្មី ")
  - ✓ កែសម្រួលព័ត៌មាន ករណីរកឃើញមានចំណុចខុសឆ្គង
  - ✓ បញ្ជូនឈ្មោះអតិថិជនដែលបានផ្ទៀងផ្ទាត់ទិន្នន័យរួច(ករណី " បានពិនិត្យរួច ") ទៅមន្ត្រីអនុម័ត
  - ✓ បោះពុម្ពបណ្ណសមធម៌ជូនអតិថិជន បន្ទាប់ពីទទួលបានការអនុម័តរួច
  - ✓ ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍

- **មន្ត្រីអនុម័តៈ**
  - ✓ ផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការសម្ភាសន៍(បញ្ជីឈ្មោះអតិថិជនដែលបានសម្ភាសន៍ ករណី “ ថ្មី ")
  - ✓ កែសម្រួលព័ត៌មាន ករណីរកឃើញមានចំណុចខុសឆ្គង
  - ✓ បញ្ជូន ឈ្មោះអតិថិជនដែលបានផ្ទៀងផ្ទាត់ទិន្នន័យរួច( ករណី “ បានពិនិត្យរួច “) ទៅមន្ត្រីអនុម័ត
  - ✓ បោះពុម្ពបណ្ណសមធម៌ជូនអតិថិជន បន្ទាប់ពីទទួលបានការអនុម័តរួច
  - ✓ ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

អ្នកសម្ភាសន៍ មន្ត្រីផ្ទៀងផ្ទាត់ និងមន្ត្រីអនុម័តដែលមានឈ្មោះខាងក្រោម បានអាន និងបញ្ជាក់ទទួលស្គាល់លើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងត្រូវធានារក្សាសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

| ឈ្មោះ | តួនាទី | ហត្ថលេខា | ថ្ងៃខែឆ្នាំ |
|---|---|---|---|
| | | | ___/___/២០__ |
| | | | ___/___/២០__ |
| | | | ___/___/២០__ |
| | | | ___/___/២០__ |

## សេចក្តីបញ្ជាក់អះអាងរបស់អ្នកប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍

អ្នកប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ មានសិទ្ធិទទួលនិងប្រើប្រាស់ទិន្នន័យចេញពីមូលដ្ឋានទិន្នន័យក្រសួងផែនការដោយអនុលោមតាមលក្ខខណ្ឌដូចខាងក្រោមៈ

- ត្រូវដាក់ពាក្យស្នើសុំធ្វើជាអ្នកប្រើប្រាស់ទិន្នន័យតាមការណែនាំរបស់ក្រសួងផែនការ
- អាចចូលប្រើប្រាស់បានតែទិន្នន័យដែលបានស្នើសុំ និងមានការអនុញ្ញាតិពីក្រសួងផែនការតែប៉ុណ្ណោះ
- អាចប្រើប្រាស់និងចែកចាយបន្តនូវទិន្នន័យដែលទទួលបានការអនុញ្ញាតិដល់ភាគីទី៣ ត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងកំឡុងពេលស្នើសុំហើយភាគីទី៣ត្រូវតែធានាអនុលោមតាមលក្ខខណ្ឌទាំងនេះផងដែរ។
- ត្រូវធានារក្សាការពារទិន្នន័យដែលទទួលបានមិនឱ្យអ្នកដទៃចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាតិពីក្រសួងផែនការ
- រាល់ការប្រើប្រាស់នូវទិន្នន័យចេញពីមូលដ្ឋានទិន្នន័យក្រសួងផែនការ ដោយផ្នែកឬទាំងស្រុងត្រូវធ្វើឡើងដោយឥតគិតថ្លៃចំពោះការប្រើប្រាស់ក្នុងគោលបំណងកិច្ចគាំពារសង្គម ការកាត់បន្ថយភាពក្រីក្រ និងបម្រើឱ្យផលប្រយោជន៍សាធារណៈ។

អ្នកប្រើប្រាស់ទិន្នន័យដែលមានឈ្មោះខាងក្រោមបានអាន និងយល់ច្បាស់អំពីខ្លឹមសារសេចក្តីបញ្ជាក់អះអាងរបស់អ្នកប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍។

| ឈ្មោះ | តួនាទី | លេខទំនាក់ទំនង | ហត្ថលេខា | ថ្ងៃខែឆ្នាំ |
|---|---|---|---|---|
| | | | | __/__/២០__ |
| | | | | __/__/២០__ |
| | | | | __/__/២០__ |
| | | | | __/__/២០__ |
| | | | | __/__/២០__ |
| | | | | __/__/២០__ |